អង្គការវេទិកាអនាគត
Future Forum Organization

# អត្ថបទវិភាគខ្លី៖ ហេតុអ្វីបានជាគណបក្សនយោបាយតូចៗ ពិបាកទទួលបានអាសនៈនៅក្នុងរដ្ឋសភា?

**ខែសីហា ឆ្នាំ២០១៧**

មានហេតុផលជាច្រើន ដែលធ្វើឱ្យគណបក្សនយោបាយតូចៗ ពិបាកទទួលបានអាសនៈនៅក្នុងរដ្ឋសភានៅកម្ពុជា។ អត្ថបទនេះធ្វើការពិភាក្សាពីកត្តា ដែលទំនងជារួមចំណែកដល់ការមិនអាចទទួលបានអាសនៈនេះ ដោយមើលទៅលើរូបមន្តបែងចែកអាសនៈ និងវិធីសាស្ត្រដែលបានអនុវត្តនៅក្នុងដំណើរការបោះឆ្នោត នៅកម្ពុជាកន្លងមក។

## សាវតា

ដូចបណ្តាប្រទេសមួយចំនួនរួមមាន ប្រទេសហ្វាំងឡង់ ស៊ុយអែត និងហូឡង់ ការបោះឆ្នោតនៅកម្ពុជាអនុវត្តតាមប្រព័ន្ធសមាមាត្រ។ គោលការណ៍នៃប្រព័ន្ធសមាមាត្រ គឺអាសនៈរបស់គណបក្សនយោបាយមួយត្រូវតែសមាមាត្រទៅនឹងសន្លឹកឆ្នោត ដែលគណបក្សនោះទទួលបាននៅក្នុងមណ្ឌលបោះឆ្នោត។[i] នៅក្រោមប្រព័ន្ធសមាមាត្រ សំឡេងឆ្នោតសរុបដែលគណបក្សនយោបាយទាំងអស់ទទួលបាន គឺកម្រនឹងត្រូវបែងចែកឲ្យគត់ទៅនឹងចំនួនអាសនៈដែលមានណាស់ នៅពេលដែលអាសនៈត្រូវបានបែងចែកដោយផ្អែកលើមូលដ្ឋានសមាមាត្រ។ ដូច្នេះហើយ សំឡេងឆ្នោតដែលនៅសល់ ចាំបាច់ត្រូវបែងចែកតាមរូបមន្តផ្សេងៗដូចជា៖ “មធ្យមភាគខ្ពស់បំផុត” (d’Hondt) “sainte-laguë” ឬ រូបមន្ត “សំណល់ធំបំផុត”។[ii] សេចក្តីសន្និដ្ឋាន និងភាពជាប់ពាក់ព័ន្ធដែលអាចមាននៃរូបមន្តទាំងនេះចំពោះបរិបទប្រទេសកម្ពុជានឹងត្រូវពិភាក្សាក្នុងអត្ថបទខ្លីនេះ។

ចាប់តាំងពីឆ្នាំ ១៩៩៣ មកប្រទេសកម្ពុជាបានអនុវត្តរូបមន្តពីរផ្សេងគ្នា ក្នុងការបែងចែកអាសនៈសម្រាប់គណបក្សនយោបាយនៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ រូបមន្ត "សំណល់ធំបំផុត" ត្រូវបានអនុម័តនៅក្នុងច្បាប់បោះឆ្នោតរបស់អង្គការសហប្រជាជាតិសម្រាប់កម្ពុជាឆ្នាំ ១៩៩២។[iii] រូបមន្តនេះត្រូវបានអនុវត្តតែម្តងគត់នៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ១៩៩៣ ដែលរូបមន្តនេះផ្តល់អាសនៈដែលនៅសល់ ឲ្យគណបក្សនយោបាយណា ដែលមានសំណល់សំឡេងឆ្នោតធំជាងគេបំផុត។[iv] រូបមន្ត "សំណល់ធំបំផុត" ត្រូវបានគេមើលឃើញជាទូទៅថា ជារូបមន្តដែលបែងចែកអាសនៈសម្រាប់គណបក្សនយោបាយដោយស្មើភាព ហើយអាចអនុញ្ញាតឱ្យគណបក្សនយោបាយតូចៗទទួលបានអាសនៈដែលនៅសល់បន្ទាប់ពីកូតា។

សម្រាប់សំនួរទាក់ទងអត្ថបទខ្លីសូមទាក់ទង កញ្ញា អេង សុខា អ្នកស្រាវជ្រាវរបស់វេទិកាអនាគត តាមទូរស័ព្ទ០១៧ ៤១ ៩០ ០៨ ឬ
sokhaaeng@gmail.com ឬ លោក អ៊ូ វីរៈ ប្រធានវេទិកាអនាគត តាមរ អ៊ីម៉ែល ouvirak@gmail.com

រូបមន្តបែងចែកអាសនៈថ្មី "មធ្យមភាគខ្ពស់បំផុត" ឬ "d'Hondt method" ត្រូវបានអនុម័តនៅក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ១៩៩៧ ហើយរូបមន្តនេះនៅតែត្រូវបានប្រើរហូតដល់សព្វថ្ងៃ។[v] នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (ច.ប.ត.រ)ដំបូងបំផុត និងបានកំណត់កាលបរិច្ឆេទការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទីពីរនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ ។ ច.ប.ត.រ ឆ្នាំ១៩៩៧ មិនត្រឹមតែបានបង្កើតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប)[vi] ប៉ុណ្ណោះទេ ថែមទាំងបានអនុម័តរូបមន្តបែងចែកអាសនៈថ្មី "មធ្យមភាគខ្ពស់បំផុត" ផងដែរ។ ច.ប.ត.រ ឆ្នាំ១៩៩៧មិនបានផ្តល់សេចក្តីលម្អិតអំពីរូបមន្តបែងចែកអាសនៈថ្មីនេះទេ គ្រាន់តែចែងនៅក្នុងមាត្រា១១៨ ថា "*ការបែងចែកអាសនៈដែលនៅសល់នៅតាមមណ្ឌលបោះឆ្នោតនីមួយៗ ត្រូវអនុវត្តតាមវិធីបែងចែកដោយយកមធ្យមភាគធំជាងគេ*"។[vii] នៅក្នុងការអនុវត្តជាក់ស្តែងចំពោះរូបមន្តនេះ អាសនៈត្រូវបានបែងចែកសម្រាប់គណបក្សនយោបាយ ដោយការគណនាអាសនៈតាមកូតាជាមុនសិន បន្ទាប់មកប្រសិនបើមានអាសនៈនៅសល់បន្ទាប់ពីកូតា ត្រូវអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុត (រូបមន្តនេះនឹងត្រូវពន្យល់លម្អិតនៅក្នុងផ្នែកបន្ទាប់)។

ឯកសារដែលអាចរកបាននៅក្នុងការសិក្សានេះ មិនបានផ្តល់ការពន្យល់ច្បាស់លាស់អំពីមូលហេតុដែលរូបមន្តបែងចែកអាសនៈថ្មីនេះត្រូវបានអនុម័តដោយរដ្ឋសភានោះទេ។ ទោះជាយ៉ាងណាក៏ដោយ គួរកត់សំគាល់ដែរថា នៅពេលដែលរូបមន្ត "មធ្យមភាគខ្ពស់បំផុត" ត្រូវបានអនុម័តក្នុងច្បាប់នៅក្នុង ច.ប.ត.រ ឆ្នាំ ១៩៩៧ មិនមានគណបក្សនយោបាយណាមួយធ្វើការជំទាស់ជាសាធារណៈនោះទេ[viii] បើទោះបីជារូបមន្តនេះផ្តល់លទ្ធភាពឲ្យគណបក្សនយោបាយធំៗ (ឧ.គណបក្សប្រជាជនកម្ពុជា) ទទួលបានអាសនៈបន្ថែមក៏ដោយ បើប្រៀបធៀបទៅនឹងរូបមន្ត "សំណល់ធំបំផុត" ដែលបានអនុវត្តកន្លងមក។[ix] បើដូច្នេះ ហេតុអ្វីបានជារូបមន្ត "មធ្យមភាគខ្ពស់បំផុត" ក្លាយជាប្រធានបទនៃការជំទាស់របស់គណបក្សប្រឆាំងបន្ទាប់ពីការបោះឆ្នោតរដ្ឋសភាឆ្នាំ ១៩៩៨? យោងតាមលោក Jeffrey Gallup "*គ.ជ.ប និងអ្នកជំនាញរបស់ខ្លួនមានកំហុសដោយសរសេររូបមន្ត "កូតា" ជំនួសឱ្យរូបមន្ត "មធ្យមភាគខ្ពស់បំផុត" ក្នុងសេចក្តីព្រាងនៃនីតិវិធីសម្រាប់ការបោះឆ្នោត... ក្រោយមក គ.ជ.ប.បានរកឃើញកំហុសរបស់ខ្លួន ហើយក៏បានកែបញ្ចូលរូបមន្ត "មធ្យមភាគខ្ពស់បំផុត" ទៅក្នុងនីតិវិធីសម្រាប់ការបោះឆ្នោតផ្លូវការដែលបានចេញផ្សាយចុងក្រោយរបស់ខ្លួនវិញ*"។ ជាលទ្ធផល គណបក្សនយោបាយផ្សេងៗ និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើនបានប្រើរូបមន្តកូតា ហើយ គ. ជ.ប ប្រើរូបមន្ត "មធ្យមភាគខ្ពស់បំផុត" ដើម្បីគណនាលទ្ធផលនៃការបោះឆ្នោតក្នុងឆ្នាំ ១៩៩៨ ។ លទ្ធផលដែលបានមកពីរូបមន្តកូតាធ្វើឱ្យគណបក្សប្រជាជន ទទួលបានចំនួនអាសនៈតិចជាងបើប្រៀបធៀបទៅនឹងរូបមន្ត "មធ្យមភាគខ្ពស់បំផុត" ដែលនេះជាមូលហេតុធ្វើឲ្យគណបក្សប្រឆាំងបានអះអាងថារូបមន្តកូតាត្រូវបានគេនិយមប្រើ ហើយគួរតែត្រូវបានអនុវត្តនៅកម្ពុជា។[x] ទោះជាយ៉ាងណាក៏ដោយរូបមន្ត "មធ្យមភាគខ្ពស់បំផុត" និង "កូតា" មានគុណវិបត្តិរៀងៗខ្លួន។

សម្រាប់គោលបំណងនៃអត្ថបទខ្លីនេះយើងផ្តោតការពិភាក្សាសំខាន់លើរូបមន្តពីរ ដែលកម្ពុជាបានអនុវត្តកន្លងមក៖ រូបមន្តសំណល់ធំបំផុត (រូបមន្តឆ្នាំ ១៩៩៣) និង មធ្យមភាគខ្ពស់បំផុត (រូបមន្តថ្មី)។

**តើរូបមន្តទាំងពីរនេះត្រូវគណនាដោយរបៀបណា?**

ឧទាហរណ៍ ខេត្តមួយមានគណបក្សនយោបាយចំនួន ៣ ចូលរួមក្នុងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្ររួមមាន គណបក្ស **ក** **ខ** និង **គ** ។ ខេត្តនេះមានអាសនៈសរុប ៥ និងមានចំនួនសន្លឹកឆ្នោតបានការសរុប ១០០.០០០ សំឡេង។ ក្នុងនោះ គណបក្ស **ក** ទទួលបាន ៦០.០០០ សំឡេង និង គណបក្ស **ខ** ទទួលបាន ២៨.០០០ សំឡេង និង គណបក្ស **គ** ទទួលបាន ១២.០០០ សំឡេង។ ដើម្បីយល់ពីរបៀបដែលរូបមន្តទាំងពីរត្រូវបានគណនា សូមមើលតារាងខាងក្រោម។

*រូបមន្តសំណល់ធំបំផុត (រូបមន្តឆ្នាំ ១៩៩៣)*

ច្បាប់បោះឆ្នោតរបស់អង្គការសហប្រជាជាតិសម្រាប់កម្ពុជាឆ្នាំ ១៩៩២ (មាត្រា៧៩) បានចែងថាដើម្បីគណនាអាសនៈសម្រាប់គណបក្សនយោបាយ ត្រូវអនុវត្តតាមវិធានមួយចំនួនដូចខាងក្រោម៖

(១) គណនាកូតាក្នុងមួយអាសនៈ (កូតា) ដោយយកចំនួនសន្លឹកឆ្នោតបានការសរុប ដែលគណបក្សទាំងអស់ទទួលបាននៅក្នុងមណ្ឌល រាជធានី/ខេត្ត ចែកនឹងចំនួនអាសនៈសរុបនៅក្នុងរាជធានី/ខេត្ត នោះ។

(២)កំណត់ចំនួនអាសនៈសម្រាប់គណបក្សនយោបាយ ដោយយកចំនួនសន្លឹកឆ្នោតបានការ ដែលគណបក្សមួយទទួលបាន ចែកនឹងកូតា។

(៣) ប្រសិនបើមានអាសនៈនៅសល់ បន្ទាប់ពីជំហានទី (២) អាសនៈដែលនៅសល់ត្រូវបែងចែកបន្តឲ្យគណបក្សណាដែលមានសំណល់សន្លឹកឆ្នោតធំជាងគេបំផុត។

| គណបក្ស | សន្លឹកឆ្នោតបានការ | កូតា (១) | អាសនៈតាមកូតា (២) | សំណល់សន្លឹកឆ្នោត | អាសនៈតាមសំណល់ធំបំផុត(៣) | អាសនៈសរុប |
|---|---|---|---|---|---|---|
| ក | ៦០.០០០ | ២០.០០០ | ៣ | ០ | ០ | ៣ |
| ខ | ២៨.០០០ | | ១ | ៨០០០ | ០ | ១ |
| គ | ១២.០០០ | | ០ | ១២០០០ | ១ | ១ |
| សរុប | ១០០.០០០ | | ៤ | | | ៥ |

*ចំណាំ៖ ដោយសារតែគណបក្សមួយត្រូវការសំឡេងឆ្នោតចំនួន ២០.០០០ ដើម្បីទទួលបានអាសនៈមួយ ដូច្នេះក្រោយពីកំណត់អាសនៈតាមកូតារួច គណបក្ស **ក** មានសំណល់សន្លឹកឆ្នោត ០ សន្លឹក គណបក្ស **ខ** នៅសល់ ៨០០០ សន្លឹក និងគណបក្ស **គ** មាន ១២.០០០ ព្រោះចំនួននេះមិនគ្រប់នឹងចំនួនកូតានៅជំហានដំបូង។ ឧទាហរណ៍នេះអាចរកបាននៅក្នុងអត្ថបទរបស់លោក Gallagher Michael (1991)"Comparing Proportional Representation Electoral Systems: Quotas, Thresholds, Paradoxes and Majorities".*

មានតែគណបក្ស **ក** និង **ខ** ដែលអាចទទួលបានអាសនៈតាមកូតានៅជំហានដំបូង ដែលគណបក្ស **ក** ទទួលបាន ៣ អាសនៈ និង **ខ** ទទួលបាន១ អាសនៈ។ ទោះជាយ៉ាងនេះក្តី មានអាសនៈ ១ ដែលនៅសល់ត្រូវបែងចែកបន្ត។ ដោយមើលទៅលើសំណល់ធំបំផុតបន្ទាប់ពីការកំណត់អាសនៈតាមកូតា គណបក្ស **គ** មានសំណល់សន្លឹកឆ្នោតច្រើនជាងគេបំផុត (១២០០០) ដូច្នេះ ១ អាសនៈដែលនៅសល់ត្រូវបែងចែកទៅគណបក្ស **គ**។

### *មធ្យមភាគខ្ពស់បំផុត (រូបមន្តថ្មី)*

រូបមន្តនេះត្រូវបានចែងនៅក្នុងមាត្រា ១៣៥ នៃច្បាប់ ច.ប.ត.រ ឆ្នាំ២០១៥។ ពីរជំហានដំបូង ក្នុងការកំណត់អាសនៈសម្រាប់គណបក្សនយោបាយមួយនៅក្នុងរាជធានី/ ខេត្ត គឺត្រូវបានគណនាដូចគ្នាទៅនឹងរូបមន្ត ឆ្នាំ ១៩៩៣ (ខាងលើ)។ ទោះយ៉ាងណាក៏ដោយ ក្នុងការអនុវត្តរូបមន្តថ្មី ប្រសិនបើមានអាសនៈនៅសល់ គេនឹងបន្តបែងចែកតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដូចការគណនាខាងក្រោម៖

មធ្យមភាគខ្ពស់បំផុត ($\text{ម}_{\text{ធ}}$) = សន្លឹកឆ្នោតបានការដែលគណបក្សនយោបាយទទួលបាន ($\text{ស}_{\text{ប}}$) ÷ ចំនួនអាសនៈដែលបានបែងចែកឲ្យគណបក្សនយោបាយមួយក្នុងជំហានទី(២) ($\text{អ}_{\text{ទ}}$) +1 ឬ $\text{ម}_{\text{ធ}} = \text{ស}_{\text{ប}} \div (\text{អ}_{\text{ទ}} + 1)$

| គណបក្ស | សន្លឹកឆ្នោតបានការ | កូតា (១) | អាសនៈតាមកូតា (២) | មធ្យមភាគខ្ពស់បំផុត ($\text{ម}_{\text{ធ}}$) | អាសនៈតាម ($\text{ម}_{\text{ធ}}$) | អាសនៈសរុប |
|---|---|---|---|---|---|---|
| ក | ៦០.000 | ២0000 | ៣ | ៦0000/(៣+១) = ១៥000 | ១ | ៤ |
| ខ | ២៨.000 | | ១ | ២៨000/(១+១) = ១៤000 | 0 | ១ |
| គ | ១២.000 | | 0 | ១២000/(0+១) = ១២000 | 0 | 0 |
| សរុប | ១00.000 | | ៤ | | | ៥ |

ដោយប្រើរូបមន្ត "មធ្យមភាគខ្ពស់បំផុត" អាសនៈដែលនៅសល់ត្រូវបាន បែងចែកឲ្យ គណបក្ស **ក** ព្រោះ **ក** មានមធ្យមភាគខ្ពស់ជាងគេបំផុត ១៥.000 ធៀបនឹង **ខ** និង **គ** ។ រូបមន្តនេះផ្តល់លទ្ធភាពឲ្យគណបក្សធំៗទទួលបានអាសនៈបន្ថែមទៀតបន្ទាប់ពីកូតា បើទោះបីជាគណបក្សនោះមិនមានសន្លឹកឆ្នោតនៅសល់បន្ទាប់ពីការកំណត់អាសនៈតាមកូតាក៏ដោយ។ ជាលទ្ធផលគណបក្ស **ក** ទទួលបាន ៤ អាសនៈហើយ **ខ** ទទួលបាន ១អាសនៈ និង **គ** មិនទទួលបានអ្វីទាំងអស់។

### តើយើងអាចរៀនអ្វីខ្លះពីឧទាហរណ៍នៃការអនុវត្តរូបមន្តទាំងនេះ?

រូបមន្តឆ្នាំ១៩៩៣ ផ្តល់ឱកាសដល់គណបក្សនយោបាយតូចៗ អាចទទួលបានអាសនៈនៅក្នុងរដ្ឋសភា ហើយរូបមន្តនេះអាចជំរុញឲ្យមានការបែងចែកអាសនៈដោយស្មើភាព សម្រាប់គណបក្សនយោបាយ ដោយការបែងចែកអាសនៈនៅសល់បន្ទាប់ពីកំណត់អាសនៈតាមកូតា ទៅគណបក្សណាដែលមានសំណល់សន្លឹកឆ្នោតច្រើនបំផុត។ ប្រសិនបើយើងបានអនុវត្តរូបមន្តឆ្នាំ១៩៩៣ ដើម្បីគណនាលទ្ធផលបោះឆ្នោតឆ្នាំ ២០១៣ នោះគណបក្សហ្វ៊ុន

ស៊ិនប៉ិចអាចទទួលបាន ៥ អាសនៈនៅក្នុងរដ្ឋសភា ព្រោះគណបក្សនេះមានចំនួនសន្លឹកឆ្នោតនៅសល់ (ឬសន្លឹកឆ្នោតមិនទាន់បានបែងចែក) ធំជាងគេនៅក្នុងមណ្ឌលបោះឆ្នោត ៥ គឺខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ធំ និងសៀមរាប។ គណបក្សប្រជាជនកម្ពុជានឹងទទួលបាន ៦៦ អាសនៈ រីឯ ៥២ អាសនៈទៀតនឹងបានទៅគណបក្សសង្គ្រោះជាតិ។

ផ្ទុយមកវិញរូបមន្តថ្មី "មធ្យមភាគខ្ពស់បំផុត" បានកំហិតឱកាសសម្រាប់គណបក្សតូចៗក្នុងការទទួលបានអាសនៈដែលនៅសល់បន្ទាប់ពីកំណត់អាសនៈតាមកូតា ព្រោះរូបមន្តនេះអនុគ្រោះដល់គណបក្សដែលទទួលបានសន្លឹកឆ្នោតច្រើនឲ្យបន្តទទួលបានអាសនៈបន្ទាប់ពីកូតា បើទោះបីជាគណបក្សនោះ មានចំនួនសន្លឹកឆ្នោតនៅសល់តិចជាងគណបក្សតូចៗក៏ដោយ។ ដូចនៅក្នុងឧទាហរណ៍ខាងលើ ក្នុងតារាងទីមួយ គណបក្ស **ក** មានមិនមានសន្លឹកឆ្នោតនៅសល់បន្ទាប់ពីកំណត់អាសនៈតាមកូតា ប៉ុន្តែគណបក្សនេះនៅតែទទួលបានអាសនៈនៅសល់ចុងក្រោយដោយសារតែមធ្យមភាគខ្ពស់បំផុត។ នៅឆ្នាំ ២០១៣ លទ្ធផលនៃការអនុវត្តរូបមន្តមធ្យមភាគខ្ពស់បំផុតគឺគណបក្សប្រជាជនទទួលបាន ៦៨ អាសនៈ គណបក្សសង្គ្រោះជាតិទទួលបាន ៥៥ និងគណបក្សហ៊្វុនស៊ិនប៉ិចមិនទទួលបានអាសនៈសូម្បីតែមួយ។

## តើត្រូវធ្វើបែបណាដើម្បីធានាថាការចែកអាសនៈមានលក្ខណៈស្មើភាព?

ដើម្បីធានាឱ្យមានការបែងចែកអាសនៈដោយស្មើភាពសម្រាប់គណបក្សនយោបាយនៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ រូបមន្តបែងចែកអាសនៈឆ្នាំ១៩៩៣ (សំណល់ធំបំផុត) គួរត្រូវបានពិចារណាយកមកអនុវត្តម្តងទៀតនៅកម្ពុជា ព្រោះរូបមន្តនេះអនុញ្ញាតឱ្យគណបក្សនយោបាយតូចៗទទួលបានអាសនៈបន្ទាប់ពីកូតា ដូច្នេះកម្ពុជាអាចមានគណបក្សនយោបាយច្រើនជាងពីរនៅក្នុងរដ្ឋសភា។ ជាងនេះទៀត រូបមន្តនេះអាចឆ្លុះបញ្ចាំងពីតម្លៃនៃសមភាពនៃសន្លឹកឆ្នោតដែលអាចបង្ហាញតាមរយៈចំនួនអាសនៈ។ គួរកត់សម្គាល់ផងដែរថា រូបមន្តមិនមែនជាកត្តាតែមួយគត់ ដែលសម្រេចចំនួនអាសនៈដែលគណបក្សនយោបាយមួយត្រូវទទួលបាននោះទេ ប៉ុន្តែចំនួនសំឡេងឆ្នោតដែលបោះឱ្យគណបក្សនយោបាយនីមួយៗ និងទំហំនៃមណ្ឌលបោះឆ្នោត (រាជធានី/ខេត្ត) ដែលមានទំនាក់ទំនងនឹងចំនួនអាសនៈនៅក្នុងរដ្ឋសភា ក៏មានសារៈសំខាន់ខ្លាំងផងដែរ។

**ឧបសម្ព័ន្ធ១៖** ប្រៀបធៀបការបែងចែកអាសនៈសម្រាប់គណបក្សនយោបាយ ដោយប្រើលទ្ធផលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០១៣[1]

| ខេត្ត | អាសនៈ | អាសនៈដែលទទួលបានដោយគណបក្សនយោបាយ ដោយប្រើរូបមន្តឆ្នាំ ១៩៩៣ | | | | អាសនៈដែលទទួលបានដោយគណបក្សនយោបាយប្រើរូបមន្តនៅក្នុងច.ប.ត.រ (អនុវត្តពីឆ្នាំ១៩៩៨ ដល់បច្ចុប្បន្ន) | | |
|---|---|---|---|---|---|---|---|---|
| | | FUN | CPP | CNRP | | FUN | CPP | CNRP |
| បន្ទាយមានជ័យ | ៦ | ១ | ៤ | ១ | | ០ | ៤ | ២ |
| បាត់ដំបង | ៨ | ១ | ៤ | ៣ | | ០ | ៥ | ៣ |
| កំពង់ចាម | ១៨ | ១ | ៨ | ៩ | | ០ | ៨ | ១០ |
| កំពង់ឆ្នាំង | ៤ | ០ | ២ | ២ | | ០ | ២ | ២ |
| កំពង់ស្ពឺ | ៦ | ០ | ៣ | ៣ | | ០ | ៣ | ៣ |
| កំពង់ធំ | ៦ | ១ | ៣ | ២ | | ០ | ៣ | ៣ |
| កំពត | ៦ | ០ | ៣ | ៣ | | ០ | ៣ | ៣ |
| កណ្តាល | ១១ | ០ | ៥ | ៦ | | ០ | ៥ | ៦ |
| កោះកុង | ១ | ០ | ១ | ០ | | ០ | ១ | ០ |
| ក្រចេះ | ៣ | ០ | ២ | ១ | | ០ | ២ | ១ |
| មណ្ឌលគិរី | ១ | ០ | ១ | ០ | | ០ | ១ | ០ |
| ភ្នំពេញ | ១២ | ០ | ៥ | ៧ | | ០ | ៥ | ៧ |
| ព្រះវិហារ | ១ | ០ | ១ | ០ | | ០ | ១ | ០ |
| ព្រៃវែង | ១១ | ០ | ៥ | ៦ | | ០ | ៥ | ៦ |
| ពោធិ៍សាត់ | ៤ | ០ | ៣ | ១ | | ០ | ៣ | ១ |
| តនៈគិរី | ១ | ០ | ១ | ០ | | ០ | ១ | ០ |
| សៀមរាប | ៦ | ១ | ៣ | ២ | | ០ | ៤ | ២ |
| ព្រះសីហនុ | ១ | ០ | ១ | ០ | | ០ | ១ | ០ |
| ស្ទឹងត្រែង | ១ | ០ | ១ | ០ | | ០ | ១ | ០ |
| ស្វាយរៀង | ៥ | ០ | ៣ | ២ | | ០ | ៣ | ២ |
| តាកែវ | ៨ | ០ | ៤ | ៤ | | ០ | ៤ | ៤ |
| កែប | ១ | ០ | ១ | ០ | | ០ | ១ | ០ |
| ប៉ៃលិន | ១ | ០ | ១ | ០ | | ០ | ១ | ០ |
| ឧត្តរមានជ័យ | ១ | ០ | ១ | ០ | | ០ | ១ | ០ |
| **សរុប** | **១២៣** | **៥** | **៦៦** | **៥២** | | **០** | **៦៨** | **៥៥** |

[1] សម្រាប់គោលបំណងនៃលំហាត់នេះវេទិកាអនាគតបានជ្រើសរើសតែគណបក្សនយោបាយចំនួនបី ដែលទទួលបានសំឡេងឆ្នោតច្រើនជាងគេក្នុងការបោះឆ្នោតឆ្នាំ២០១៣។ ជាថ្មីម្តងទៀតកូតាតាមខេត្ត/រាជធានីត្រូវបានកំណត់ដោយការចែកសន្លឹកឆ្នោតបានការសរុបដែលគណបក្សនយោបាយទាំងអស់ទទួលបាននៅក្នុងខេត្ត/រាជធានី នឹងចំនួនអាសនៈក្នុងខេត្ត/រាជធានីនោះ។ ទិន្នន័យលទ្ធផលនៃការបោះឆ្នោត ២០១៣ បានមកពី លទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឆ្នាំ២០១៣ ដែលចេញផ្សាយដោយគ.ជ.ប។

[i] Norris Pippa (១៩៩៧) "ការជ្រើសរើសប្រព័ន្ធបោះឆ្នោត៖ ប្រព័ន្ធសមាមាត្រ សំឡេងភាគច្រើន និងប្រព័ន្ធចំរុះ" សាកលវិទ្យាល័យហារើដ

[ii] Gallagher Michael (១៩៩១) "ភាពសមាមាត្រ ភាពមិនសមាមាត្រ និងប្រព័ន្ធបោះឆ្នោត" *ការសិក្សាអំពីការបោះឆ្នោត។* ទំព័រ៣៣

[iii] Jeffrey Gallup (២០០២) "ប្រព័ន្ធបោះឆ្នោតនៅកម្ពុជា៖ឱកាសសម្រាប់កំណែទម្រង់"។ នយោបាយនៃការបោះឆ្នោតនៅអាស៊ីអាគ្នេយ៍ និងអាស៊ីខាងកើត។

[iv] Norris Pippa (១៩៩៧) "ការជ្រើសរើសប្រព័ន្ធបោះឆ្នោត៖ ប្រព័ន្ធសមាមាត្រ សំឡេងភាគច្រើន និងប្រព័ន្ធចំរុះ"សាកលវិទ្យាល័យហារើដ

[v] មាត្រា ១៣៥ នៃ ច.ប.ត.រ (២០១៥) "*ការបែងចែកអាសនៈរាជធានី ខេត្តត្រូវធ្វើឡើងតាមរូបមន្តមធ្យមភាគខ្ពស់បំផុតដោយផ្អែកលើចំនួនអាសនៈក្នុងរាជធានី ខេត្ត និងលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានីខេត្ត..*"

[vi] គ.ជ.ប ប្រវត្តិ គ.ជ.ប ។ មាននៅ www.necelect.org.kh/khmer/content/2. ប្រឹក្សានៅថ្ងៃទី១២ កក្កដា ២០១៧។

[vii] កម្ពុជា៖ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ១៩៩៧, មាត្រា១១៨. ២៦ ធ្នូ ១៩៩៧។ មាននៅ www.refworld.org/docid/3ae6b5448.html ប្រឹក្សានៅថ្ងៃទី១២ កក្កដា ២០១៧។

[viii] Jeffrey Gallup (២០០២) "ប្រព័ន្ធបោះឆ្នោតនៅកម្ពុជា៖ឱកាសសម្រាប់កំណែទម្រង់"។ នយោបាយនៃការបោះឆ្នោតនៅអាស៊ីអាគ្នេយ៍ និងអាស៊ីខាងកើត។

[ix] Gallagher Michael.ប្រៀបធៀបប្រព័ន្ធបោះឆ្នោតសមាមាត្រ៖ កូតា, កម្រិតទាបឬខ្ពស់បំផុត, មតិផ្ទុយពីមតិធម្មតា និងសំឡេងភាគច្រើន។ នាយកដ្ឋានវិទ្យាសាស្ត្រនយោបាយ សាកលវិទ្យាល័យដុបលីន។

[x] Jeffrey Gallup (២០០២) "ប្រព័ន្ធបោះឆ្នោតនៅកម្ពុជា៖ឱកាសសម្រាប់កំណែទម្រង់"។ នយោបាយនៃការបោះឆ្នោតនៅអាស៊ីអាគ្នេយ៍ និងអាស៊ីខាងកើត ។ ទំព័រ៤៨។